## នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

**ភាគីដាក់ឯកសារ:** អ្នកដែលមិនមែនជាភាគីនៃរឿងក្តី

**ដាក់ជូន:** សហចៅក្រមស៊ើបអង្កេត

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2016, 13:46
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖** សាធារណៈ/Public

**ចំណាត់ថ្នាក់ប្រភេទឯកសារ៖**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖**

**ឈ្មោះមន្ត្រីកត់ត្រា៖**

**ហត្ថលេខា៖**

---

**សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ដែលដាក់ជូនដោយបណ្ឌិត WILLIAMS និង GREY ក្នុងការឆ្លើយតបទៅនឹងការអំពាវនាវឲ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ក្នុងសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦**

---

**ដាក់ដោយ÷**

**អ្នកដែលមិនមែនជាភាគីនៃរឿងក្តី**

**បណ្ឌិត** SARAH WILLIAMS និង **បណ្ឌិត** ROSEMARY GREY

**សេចក្តីផ្តើម**

១. សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីនេះត្រូវបានដាក់ ដោយអនុលោមតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុង និងជាការឆ្លើយតបទៅនឹងការអំពាវនាវឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងត្រូវបានចុះកាលបរិច្ឆេទថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦[1]។ សាស្ត្រាចារ្យរង Sarah Williams និងបណ្ឌិត Rosemary Grey ជាអ្នកធ្វើសេចក្តីព្រាងសារណានេះ។ អ្នកទាំងពីរគឺជាអ្នកស្រាវជ្រាវជាន់ខ្ពស់ដែលកំពុងបំពេញការងារលើវិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដូចដែលបានរៀបរាប់ពិស្តារក្នុងជីវប្រវត្តិសិក្សាដែលបានភ្ជាប់មកជាមួយ។ បណ្ឌិត Williams បានបង្ហាញពីទំនាក់ទំនងដែលមានស្រាប់កន្លងមកជាមួយនឹងចៅក្រម Bohlander ថាជាអ្នកត្រួតពិនិត្យម្នាក់ក្នុងចំណោមអ្នកត្រួតពិនិត្យថ្នាក់បណ្ឌិតរបស់គាត់ (ដែលបានដាក់ នៅឆ្នាំ ២០០៩) និងជាអតីតមិត្តរួមការងាររបស់គាត់។

២. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានស្នើសុំឱ្យមានការដាក់សារណាទាក់ទង "ថាតើនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមានពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការវាយប្រហារដែលធ្វើឡើងដោយរដ្ឋ ឬអង្គការប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនផ្ទាល់ អាចជាការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល នៅក្រោមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែរឬយ៉ាងណា"។

៣. សារណានេះលើកទឡ្ហីករណ៍ថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនរបស់រដ្ឋមួយអាចនឹងត្រូវបានចាត់ទុកជា "ជនស៊ីវិល" ផ្អែកតាមខ្លឹមសារនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលប្រព្រឹត្តឡើងដោយរដ្ឋផ្ទាល់របស់ពួកគេក្នុងស្ថានភាពពីរយ៉ាងគឺ៖

ក. ក្នុងករណីដែលបុគ្គលទាំងនោះត្រូវបានវាយប្រហារ នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ ដោយសារតែភក្តីភាពដែលត្រូវសន្មត់ចំពោះភាគីមួយទៀតក្នុងជម្លោះ ឬដោយសារមូលហេតុដែលមិនទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ ជាពិសេសដោយសារមូលហេតុរើសអើង និង

ខ. ក្នុងករណីដែលការវាយប្រហារត្រូវបានប្រព្រឹត្តក្នុងពេលមានសន្តិភាព

[1] អ.វ.ត.ក, ការអំពាវនាវឱ្យដាក់សារណាដោយភាគីក្នុងសំណុំរឿង ០០៣ និង ០០៤ និងការអំពាវនាវឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី។ ០០៣/០១-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦។

លើសពីនេះទៀត សមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋមួយអាចត្រូវបានចាត់ទុកថាជា*ជនរងគ្រោះ*នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងករណីដែលឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធ គឺជាផ្នែកមួយនៃការវាយប្រហារទូលំទូលាយប្រឆាំងនឹងប្រជាជនដែលភាគច្រើនជា "ជនស៊ីវិល"។

## **ឧទ្ទិករណ៍**

### **ប្រជាជន*ស៊ីវិល***

៤. មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវតែប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារយ៉ាងរាលដាល ឬជាប្រព័ន្ធដែលសំដៅទៅលើ "ប្រជាជន*ស៊ីវិល*" (បន្ថែមការបញ្ជាក់)។

៥. ពាក្យថា "ជនស៊ីវិល" មិនត្រូវបាកំណត់និយមន័យច្បាស់លាស់ឡើយនៅក្នុងលិខិតុបករណ៍នៃច្បាប់អន្តរជាតិ នៅមុនពិធីសារបន្ថែមលើកដំបូងសម្រាប់អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ដែលចែងថា "ប្រជាជនស៊ីវិល" គឺជាប្រជាជនដែលសំដៅលើបុគ្គលទាំងឡាយណាដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ[2]។ ទោះបីជាពិធីសារបន្ថែមនេះមិនត្រូវបានអនុម័តឲ្យប្រើប្រាស់រហូតដល់ឆ្នាំ ១៩៧៧ ក្តី ក៏និយមន័យនៃ "ជនស៊ីវិល" នេះត្រូវបានទទួលយកយ៉ាងទូលំទូលាយនៅមុនពេលនោះ។ នៅឆ្នាំ ១៩៤៨ គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ បានបញ្ជាក់ថា ពាក្យថា "ប្រជាជនស៊ីវិល" ដូចមានការប្រើប្រាស់ក្នុងបញ្ញត្តិអំពី ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិ "ហាក់ចង្អុលបង្ហាញថា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ត្រូវបានរឹតត្បិតតែចំពោះឧក្រិដ្ឋកម្មណាដែលប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិល មិនមែនប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធនោះទេ[3]។

---

[2] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ, *បទអត្ថាធិប្បាយនៃឆ្នាំ ១៩៨៧៖ ពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និង ទាក់ទងទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ (ពិធីសារទី ១) ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧*, កថាខណ្ឌ ១៩១២-១៩១៣។

[3] *ប្រវត្តិសាស្ត្រទាំងស្រុងនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ និងការអភិវឌ្ឍច្បាប់សង្គ្រាម*។ ចងក្រងដោយគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ។ បោះពុម្ពផ្សាយសម្រាប់គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិដោយ His Majesty's Stationary Office (ទីក្រុងឡុងដ៍ ឆ្នាំ ១៩៤៨), ទំព័រ ១៩៣។

៦. ការដាក់បញ្ចូលពាក្យ "ជនស៊ីវិល" នេះនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឆ្លុះបញ្ចាំងពីការពិតដែលថា "គោលការណ៍នៃការការពារប្រជាជនស៊ីវិលគឺមិនអាចញែកដាច់ចេញពីគោលការណ៍នៃភាពខុសគ្នាដែលគប្បីធ្វើឡើងរវាងកងកម្លាំងនយោធា និងប្រជាជនស៊ីវិលបានឡើយ"[4]។ ដូច្នេះពាក្យថា "ជនស៊ីវិល" មានគោលបំណងជាក់ស្តែងមួយ៖ ពាក្យនេះអាចត្រូវបានដកចេញពីភាពខុសគ្នាផ្នែកច្បាប់រវាងអ្នក ដែលអាចត្រូវបានកំណត់ជាគោលដៅដោយស្របច្បាប់ នៅក្នុងជម្លោះប្រដាប់អាវុធ ដោយអនុលោមតាមច្បាប់មនុស្សធម៌អន្តរជាតិ និងអ្នកដែលមិនអាចត្រូវបានកំណត់ជាគោលដៅ[5]។ នោះមានន័យថា ពាក្យនេះដកចេញពីវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រង់ចំណុច "សកម្មភាពយោធា ប្រឆាំងនឹងគោលបំណងយោធាស្របច្បាប់ដោយអនុលោម តាមច្បាប់មនុស្សធម៌អន្តរជាតិ"[6]។

៧. ស្របតាមយុទ្ធសាស្ត្រនេះ យុទ្ធសាស្ត្រជាធរមានបង្ហាញថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធនឹងមិនត្រូវបានចាត់ទុកថាជា "ប្រជាជនស៊ីវិល" ឡើយ ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានសម្រេចថា សមាជិកគ្រប់រូបនៃកងកម្លាំងប្រដាប់អាវុធមិនមែនជាប្រជាជនស៊ីវិល តាមខ្លឹមសារនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ។ ប្រការនេះគឺមិនគិតឡើយថាតើពួកគេជា*អ្នកដែលបាត់បង់សមត្ថភាពប្រយុទ្ធ* ឬអត់ នៅពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត[7]។

៨. ទោះយ៉ាងណា យុទ្ធសាស្ត្រជាធរមាន ជាទូទៅមិនបានពិចារណាលើស្ថានភាពនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ហើយក៏មិនបានពិចារណាលើស្ថានភាពរបស់សមាជិកនៃកងកម្លាំងប្រដាប់អាវុធក្នុងពេលមានសន្តិភាពដែរ។

---

[4] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ, *បទអត្ថាធិប្បាយ*លេខ ២, កថាខណ្ឌ ១៩១១។

[5] Robert Cyrer, Håkan Friman, Darryl Robinson និង Elizabeth Wilmshurst, *សេចក្តីផ្តើមអំពីច្បាប់ និងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ (បោះពុម្ពលើកទី ៣)* (Cambridge University Press ទីក្រុង Cambridge ឆ្នាំ ២០១៤), ទំព័រ ២៤១។ សូមមើលផងដែរសារណាបណ្តឹងសាទុក្ខរបស់ព្រះរាជអាជ្ញា, *ព្រះរាជអាជ្ញា* v Milan Martić, IT-95-11-A, កថាខណ្ឌ ៣-៥។

[6] Cryer, ដូចឯកសារខាងលើ, ២៤១។

[7] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Blaškićv* (IT-៩៥-១៤-A) សាលដីកាបណ្តឹងសាទុក្ខ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤, កថាខណ្ឌ ១១៤; រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Milan Martić*, សាលដីកាបណ្តឹងសាទុក្ខ ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០០៨, កថាខណ្ឌ ២៩៥។

## ការវាយប្រហារប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ

៩. ពាក្យថា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ត្រូវបានកំណត់និយមន័យជាលើកដំបូងនៅក្នុងធម្មនុញ្ញឆ្នាំ ១៩៤៥ នៃតុលាការយោធាអន្តរជាតិ ដែលសំដៅលើអំពើជាក់លាក់នានាដែលប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារលើប្រជាជនស៊ីវិលណាមួយ"[8]។ ពាក្យថា "ណាមួយ" ត្រូវ បានរួមបញ្ចូលនៅក្នុងនិយមន័យនេះដើម្បីទទួលស្គាល់ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអាចត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិលសញ្ជាតិ "ណាមួយ" ហើយដូច្នេះការពារប្រជាជនផ្ទាល់របស់រដ្ឋមួយនៅក្នុងស្ថានភាពដែលច្បាប់មនុស្សធម៌អន្តរជាតិមិនអាចការពារបាន[9]។ ការអភិវឌ្ឍផ្នែកច្បាប់នេះគឺជា "ការរីកចម្រើនដ៏សំខាន់" មួយ ដោយសារ មុនពេលមានចលនាសិទ្ធិមនុស្ស ច្បាប់អន្តរជាតិជាទូទៅកំណត់ការប្រព្រឹត្តិរបស់រដ្ឋនានា និងមិនមែនការប្រព្រឹត្តិរបស់រដ្ឋមួយទៅលើពលរដ្ឋរបស់ខ្លួនផ្ទាល់ទេ[10]។ ហេតុនេះហើយ ចំណុចដែលថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធអាចជាជនជាតិកម្ពុជា មិនបានច្រានចោលសកម្មភាពរបស់រដ្ឋ ប្រឆាំងនឹងពួកគេពីការបង្កើតឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អនុលោមតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

១០. ច្បាប់មនុស្សជាតិអន្តរជាតិកំណត់ជាសំខាន់លើទង្វើ ដែលធ្វើឡើងសំដៅដល់កងកម្លាំងប្រឆាំង និងអ្នកដែលធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់សត្រូវ (ជនស៊ីវិល ឈ្លើយសឹក អ្នកជំងឺ និងអ្នករបួស)[11]។ ច្បាប់នេះជាទូទៅមិនកំណត់ពីការប្រព្រឹត្តិចំពោះកងកម្លាំង ឬប្រជាជនផ្ទាល់របស់រដ្ឋឡើយ បើទោះបីជាមានករណីលើកលែងកំពុងលេចឡើងមួយចំនួនចំពោះគោលការណ៍នេះក្តី[12]។ ហេតុនេះហើយ បទប្បញ្ញត្តិនៅក្នុងច្បាប់មនុស្សជាតិអន្តរជាតិពាក់ព័ន្ធនឹងស្ថានភាពជនស៊ីវិល ដែលនាំឲ្យមានការឲ្យ

---

[8] ធម្មនុញ្ញតុលាការយោធាអន្តរជាតិ មាត្រា ៦(គ)។

[9] Rodney Dixon និង Christopher Hall, "មាត្រា ៧" នៅក្នុង Otto Triffterer (ed) *បទអត្ថាធិប្បាយស្តីពីលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ កំណត់ត្រារបស់ក្រុមអ្នកសង្កេតការណ៍ មួយមាត្រាម្តងៗ (បោះពុម្ពលើកទី ២)* (CH Beck, Hart និង Nomos, ឆ្នាំ ២០០៨), ទំព័រ ១៨១។

[10] Cyrer និងអ្នកដទៃទៀត (លេខ ៥), ទំព័រ ២៣០។

[11] *Cryer* និងអ្នកដទៃទៀត, លេខ ៥, ទំព័រ ២៨៥។

[12] សូមមើល ឧទាហរណ៍៖ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ, រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Bosco Ntaganda* សេចក្តីសម្រេចអនុលោមតាមមាត្រា ៦១(៧) (ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីការចោទប្រកាន់របស់ព្រះរាជអាជ្ញាប្រឆាំងនឹង Bosco Ntaganda, ICC-01/04-02/06-309, ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៩, អង្គបុរេជំនុំជម្រះលើកទី ២, កថាខណ្ឌ ៧៤-៨២។

និយមន័យនៃប្រជាជនស៊ីវិល ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនទាន់បានអនុវត្តរួចឡើយ ចំពោះសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនរបស់រដ្ឋមួយ។

១១. ជាពិសេស មាត្រា ៥០ នៃពិធីសារបន្ថែមលើកដំបូងលើអនុសញ្ញាទីក្រុងហ្សឺណែវកំណត់និយមន័យ "ជនស៊ីវិល" ដោយយោងទៅដល់អ្នកដែលមានសិទ្ធិទទួលបានឋានៈជា ឈ្លើយសឹកក្រោម មាត្រា ៤ ក នៃអនុសញ្ញាទីក្រុងហ្សឺណែវទីបី។ និយមន័យនេះរួមបញ្ចូលទាំង "សមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលជាភាគីមួយនៃជម្លោះ ក៏ដូចជាសមាជិកនៃកងជីវពល ឬអ្នកស្ម័គ្រចិត្តដែលបង្កើតជាផ្នែកមួយនៃកងកម្លាំងប្រដាប់អាវុធបែបនោះ"។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងទី ៣ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនៅក្នុងរឿងក្តី *Prlić* បានកត់សម្គាល់៖ "ការបកស្រាយដោយមានការបង្ហាញភ័ស្តុតាងដែលព្យាយាមបង្ហាញពីគោលដៅនៃអនុសញ្ញាលើកទីបីនាំទៅដល់ការសន្និដ្ឋានយ៉ាងច្បាស់ថា មានតែបុគ្គលទាំងឡាយណាដែលស្ថិតក្នុងកងកម្លាំងប្រដាប់អាវុធនៃភាគីមួយ មិនមែនជាភាគីដែលត្រូវឃាត់ខ្លួនប៉ុណ្ណោះ ទើបត្រូវបានយកមកពិចារណា"[13]។

១២. លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងទី ៣ ចាត់ទុកថា "សមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ភាគីមួយនៃជម្លោះ អាចនឹងមិនត្រូវបានចាត់ទុកថាជាឈ្លើយសឹកឡើយ នៅពេលពួកគេត្រូវបានឃុំខ្លួនដោយកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់ខ្លួន" ពីព្រោះថា ពួកគេមិនអាចត្រូវបានចាត់ទុកថាបាន "ធ្លាក់ចូលក្នុងអំណាចរបស់សត្រូវ" នៅក្នុងអត្ថន័យនៃមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវទីបី[14]។

១៣. ដោយបានសម្រេចថា ប្រជាជនមូស្លីមនៅក្នុងក្រុមប្រឹក្សាការពារជាតិក្រូអាស៊ីដែលត្រូវបានឃុំខ្លួនដោយសមាជិកដទៃទៀតនៃក្រុម មិនអាចជាឈ្លើយសឹកនោះ អង្គជំនុំជម្រះសាលាដំបូងទី ៣ បានបញ្ជាក់ថា ប្រជាជនមូស្លីមដែលត្រូវបានឃុំខ្លួន តាមពិតគឺជាប្រជាជនដែលត្រូវបានការពារនៅ ក្នុង

[13] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកដទៃទៀត* (IT-04-74) សាលដីកា ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣, អង្គជំនុំជម្រះសាលាដំបូងលើកទី ៣, វ៉ុល ៣, កថាខណ្ឌ ៦០៣។

[14] រឿងក្តី *Prlić* កថាខណ្ឌ ៦០៤

អត្ថន័យនៃមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវទីបួន"[15]។ ដោយសារតែអនុសញ្ញាទីក្រុងហ្សឺណែវទីបួនទាក់ទងទៅនឹង "ការការពារ*ជនស៊ីវិល*នៅក្នុងពេលមានសង្គ្រាម" សេចក្តីសម្រេចនេះបានបង្ហាញថា សមាជិកនៃកងកម្លាំង ឬក្រុមប្រដាប់អាវុធជា "ជនស៊ីវិល" ឬយ៉ាងហោចណាស់ទទួលបានការការពារតាមផ្លូវច្បាប់ដូចគ្នានឹង "ជនស៊ីវិល" នៅពេលដែលត្រូវបានឃុំខ្លួនដោយរដ្ឋ ឬក្រុមរបស់ខ្លួនផ្ទាល់។

១៤. បុគ្គលដែលត្រូវបានឃុំខ្លួននៅក្នុងរឿងក្តី *Prlić* ត្រូវបានឃុំខ្លួន ខណៈពេលដែលពួកគេត្រូវបានគេមើលឃើញថាជាការគំរាមកំហែងខាងសន្តិសុខ ដោយសារតែភក្តីភាពដែលគេយល់ឃើញចំពោះភាគីប្រឆាំង។ អង្គជំនុំជម្រះសាលាដំបូងទី ៣ ពឹងផ្អែកលើលក្ខណៈវិនិច្ឆ័យនៃភក្តីភាព មិនមែនសញ្ជាតិទេ ដើម្បីសម្រេចថា បុគ្គលទាំងនេះបានធ្លាក់ចូលទៅក្នុងកណ្តាប់ដៃនៃ "អំណាចរបស់សត្រូវ" អនុលោមតាមអនុសញ្ញាទីក្រុងហ្សឺណែវទីបួន[16]។

១៥. យុទ្ធសាស្ត្រដែលអនុម័តដោយអង្គជំនុំជម្រះសាលាដំបូង គឺស្របគ្នាជាមួយនឹងយុទ្ធសាស្ត្រជាក់ស្តែងក្នុងការកំណត់និយមន័យនៃ "ជនស៊ីវិល" ផ្អែកតាមខ្លឹមសារនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ច្បាប់មនុស្សជាតិអន្តរជាតិ មិនបានចាត់ទុកសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋមួយថាជាយុទ្ធជនឡើយ ហើយគ្មានតម្រូវឲ្យបែងចែកសមាជិកនៃកងកម្លាំងប្រដាប់អាវុធចេញពីប្រជាជនស៊ីវិលនោះដែរ។ ដូច្នេះ នៅចំណុចដែលសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋត្រូវបានកំណត់គោលដៅ ដោយសារតែភក្តីភាពដែលគេយល់ឃើញចំពោះភាគីមួយផ្សេងទៀតក្នុងជម្លោះ ពួកគេគប្បីត្រូវបានចាត់ទុកថាជាជនស៊ីវិល ផ្អែកតាមខ្លឹមសារនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

១៦. លើសពីនេះទៀត ក្នុងករណីដែលសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋមួយត្រូវបានកំណត់ជាគោលដៅដោយរដ្ឋរបស់គេផ្ទាល់ ដោយសារហេតុផលដែលមិនទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ ពួកគេគប្បីត្រូវបានចាត់ទុកថាជាជនស៊ីវិល ផ្អែកលើខ្លឹមសារនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ប្រការនេះគឺបែបនេះ ជាពិសេសក្នុងករណីដែលពួកគេត្រូវបានកំណត់ជាគោលដៅដោយសារហេតុផលរើសអើង ឧទាហរណ៍ ដោយផ្អែកលើមូលដ្ឋានពូជសាសន៍ ជាតិពន្ធុ សាសនា ការគាំទ្រ

---

[15] រឿងក្តី *Prlić*, កថាខណ្ឌ ៦១១។ កម្មវត្ថុនៃការប្តឹងឧទ្ធរណ៍៖ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Prlić *និងអ្នកដទៃទៀត* (IT-04-74) "សេចក្តីជូនដំណឹងអំពីការដាក់សំណើសុំកែតម្រូវដល់សាធារណជននូវកំណែតែងសេចក្តីសារណារបស់ម្ចាស់បណ្តឹងសាទុក្ខរបស់ Bruno Stojič ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, កថាខណ្ឌ ៣៨៦-៣៩១។

[16] *ដូចឯកសារខាងលើ*, កថាខណ្ឌ ៦០៨-៦១០។

ឬប្រឆាំងទៅនឹងមនោគមវិជ្ជាជាក់លាក់មួយ។ ប្រការនេះគឺស្របជាមួយនឹងជំហរដែលត្រូវបានប្រកាន់យកនៅក្នុងករណីក្រោយសង្គ្រាមលោកលើកទី ២ ដោយមានការបញ្ជាក់ថា សមាជិកនៃចលនាតស៊ូត្រូវបានកំណត់ជាគោលដៅដោយសារតែសាសនា ឬការប្រឆាំងរបស់ខ្លួនទៅនឹងមនោគមវិជ្ជាជាក់លាក់មួយ និងមិនមែន ដោយសារតែពួកគេជាយុទ្ធជនឡើយ[17]។

១៧. គួរមានការកត់សម្គាល់ថា គ្មានការផ្តល់យោបល់ណាដែលថា ប្រជាជនមូស្លីមដែលត្រូវបានឃុំខ្លួននៅក្នុងរឿងក្តី *Prlić* បានចូលរួមយ៉ាងសកម្មនៅក្នុងអរិភាពប្រឆាំងនឹងក្រុមរបស់ពួកគេផ្ទាល់ (ក្រុមប្រឹក្សាការពារជាតិក្រូអាស៊ី) នោះទេ។ ប៉ុន្តែ បើទោះជាពួកគេបានធ្វើដូច្នេះមែន (ឧទាហរណ៍ បានចូលរួមជាមួយកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ឬភាគីផ្សេងទៀតក្នុងជម្លោះ) ក៏វិធីសាស្ត្រជាក់ស្តែងនឹងតម្រូវឲ្យពួកគេត្រូវបានគេចាត់ទុកថាជាយុទ្ធជន មិនមែនជនស៊ីវិលទេ។ បុគ្គលបែបនោះអាចត្រូវបានកំណត់ជាគោលដៅដោយស្របច្បាប់ នៅក្រោមច្បាប់មនុស្សជាតិអន្តរជាតិ ហើយត្រូវតែបែងចែកចេញពីប្រជាជនស៊ីវិល។ ឲ្យតែមានការវាយប្រហារណាមួយប្រឆាំងនឹងបុគ្គលបែបនោះ *ដោយសារ*តែតួនាទីពិតប្រាកដរបស់ខ្លួននៅក្នុងជម្លោះប្រដាប់អាវុធ ជំនួសឲ្យក្រុមប្រដាប់អាវុធមួយផ្សេងទៀត ការធ្វើទុក្ខបុកម្នេញដែលរងការចោទប្រកាន់ណាមួយ គប្បីត្រូវបានពិនិត្យថាជាឧក្រិដ្ឋកម្មសង្គ្រាមដ៏មានសក្តានុពល មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

**ការវាយប្រហារប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋក្នុងពេលមានសន្តិភាព**

១៨. តាមការយល់ដឹងរបស់យើង យុទ្ធសាស្ត្រដែលមានស្រាប់មិនបានពិចារណាជាពិសេសលើស្ថានភាពនៃសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋមួយ ដោយផ្អែកលើខ្លឹមសារនៃ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងក្នុងពេលមានសន្តិភាពទេ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានទទួលស្គាល់ ជាដំបូងថាជាឧក្រិដ្ឋកម្មដែលផ្សារភ្ជាប់ទៅនឹងជម្លោះប្រដាប់អាវុធ ទោះបីជាការផ្សារភ្ជាប់ទៅនឹងជម្លោះប្រដាប់អាវុធនេះលែងត្រូវបានគេទាមទារទៀត ដោយសារច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ ១៩៧៥ ក៏ដោយ[18]។

---

[17] តុលាការកំពូលព្រហ្មទណ្ឌបារាំង រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Barbie ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៨៥, ៧៨ ILR ១២៤, ១៤០; សាលាឧទ្ធរណ៍នៃទីក្រុងប៉ារីស, *អយ្យការ តទល់នឹង* Touvier ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៩២, ១០០ ILR ៣៣៧, ៣៥២។

[18] ECCC-003-D87/2/1.7/1 សេចក្តីសម្រេចលើសំណើសុំបំភ្លឺរបស់មាស មុតទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងទាក់ទងនឹងជម្លោះប្រដាប់អាវុធ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៦។

១៩. ដូចបានរៀបរាប់ខាងលើ ពាក្យថា "ជនស៊ីវិល" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានដកយកអត្ថន័យរបស់វាពីច្បាប់មនុស្សជាតិអន្តរជាតិ ដែលមិនបានកំណត់លើស្ថានភាពនៃបុគ្គលទាំងអស់ក្នុងពេលមានសន្តិភាពឡើយ។ ដូច្នេះ ការយកចិត្តទុកដាក់ដ៏ធំធេងចាំបាច់ត្រូវមាន នៅពេលទាញយកនិយមន័យពីច្បាប់មនុស្សជាតិអន្តរជាតិ ដើម្បីកំណត់វិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តក្នុងពេលមានសន្តិភាព។ ពាក្យថា "ជនស៊ីវិល" គ្មានអត្ថន័យទេ ហើយពិតណាស់មិនបម្រើឲ្យមុខងារណាមួយឡើយ នៅពេលដែលគ្មានជម្លោះប្រដាប់អាវុធ ហើយដូច្នេះមិនតម្រូវឲ្យមានការបែងចែករវាងជនស៊ីវិល និងយុទ្ធជនឡើយ។

២០. ដូច្នេះ សមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋគប្បីត្រូវចាត់ទុកថាជា "ជនស៊ីវិល" តាមខ្លឹមសារនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលប្រព្រឹត្តដោយរដ្ឋក្នុងពេលមានសន្តិភាព[19]។ រឿងនេះគឺដូច្នេះមែន សូម្បីតែក្នុងករណីដែលមានការវាយប្រហារទៅលើកងកម្លាំងប្រដាប់អាវុធជាក់លាក់ និងមិនមែនជាផ្នែកនៃការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលទូលំទូលាយជាងនេះក៏ដោយ។ បើមិនដូច្នោះទេ វានឹងផ្ទុយពីវត្ថុបំណង និងគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវការពារប្រឆាំងនឹង "រាល់សកម្មភាពដែលកំពុងកើតឡើង ផ្ទុយទៅនឹងតម្លៃជាមូលដ្ឋានទាំងនោះដែលត្រូវបាន ឬគួរតែត្រូវបានចាត់ទុកថាមានជាប់ជាមួយនឹងមនុស្សជាតិ"[20]។ វាក៏នឹងផ្ទុយគ្នាទៅនឹងលិខិតុបករណ៍សិទ្ធិមនុស្សដូចជាអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម ដែលគ្រប់គ្រងលើការធ្វើទុក្ខបុកម្នេញក្នុងអំឡុងពេលមានសន្តិភាព និងមិនបែងចែកភាពខុសគ្នារវាងជនរងគ្រោះជាយោធា និងជនរងគ្រោះមិនមែនយោធាទេ។

***គោលការណ៍គ្មានច្បាប់គឺគ្មានទោស***

២១. ការទទួលស្គាល់សមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលបានកំណត់ជាគោលដៅ ដោយរដ្ឋផ្ទាល់របស់ពួកគេថាជា "ជនស៊ីវិល" ផ្អែកតាមខ្លឹមសារនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នឹងស្របគ្នាជាមួយនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥។ ការបកស្រាយនេះឆ្លុះបញ្ចាំងពីតួនាទីជាក់ស្តែងដែលអនុវត្តដោយពាក្យថា "ប្រជាជនស៊ីវិល" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានទទួលស្គាល់យ៉ាងហោចណាស់ពីឆ្នាំ ១៩៤៥។

---

[19] A Cassese និង P Gaeta, *ច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិរបស់ Cassese* បោះពុម្ពលើកទី ៣ (ឆ្នាំ ២០១៣) ទំព័រ ១០៥។

[20] ដូចឯកសារខាងលើ, ទំព័រ ៨៧។

២២. កង្វះខាតនៃប្រភពព័ត៌មានចាំបាច់ គឺមិនមែនមិនស្របគ្នាជាមួយជំហរនេះទេ ប៉ុន្តែផ្ទុយទៅវិញ វាបង្ហាញថា បញ្ហានេះមិនទាន់បានលេចឡើងសម្រាប់ធ្វើការសម្រេចនោះទេ។ រឿងក្តីជាច្រើននៅក្រោយសង្គ្រាមលោកលើកទី ២ បានទទួលស្គាល់ថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬចលនាតស៊ូអាចជាជនស៊ីវិល នៅក្នុងកាលៈទេសៈជាក់លាក់ ដូចដែលយុទ្ធសាស្ត្រតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដាទទួលស្គាល់ពីពេលមុននេះដែរ។

២៣. វាអាចនឹងមានបញ្ហាមួយដែលទាក់ទងនឹងថាតើ អ្នកដែលរងការចោទប្រកាន់អាចដឹងជាមុន ឬអត់ថា ការកំណត់គោលដៅដោយចេតនាលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ដែលគេជឿថាកំពុងគាំទ្រភាគីមួយផ្សេងទៀតចំពោះជម្លោះនេះ អាចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ចំណុចនេះអាចពឹងផ្អែកលើបទប្បញ្ញត្តិពាក់ព័ន្ធនានារបស់កម្ពុជា និងច្បាប់វិន័យយោធាផ្សេងៗទៀតនៅក្នុងឆ្នាំ ១៩៧៥។ ទោះជាយ៉ាងណា ការវាយប្រហារដោយចេតនាលើបុគ្គល ដែលគ្មាននីតិវិធីត្រឹមត្រូវ និងនាំឱ្យមានការសម្លាប់ និងការធ្វើទុក្ខបុកម្នេញ ទំនងជានឹងលើសពីវិសាលភាពដែលច្បាប់អនុញ្ញាត។

## ឧក្រិដ្ឋកម្មប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធនឹងមិនផ្លាស់ប្តូរលក្ខណៈនៃប្រជាជនស៊ីវិលឡើយ

២៤. សូម្បីតែក្នុងករណីដែលសមាជិកម្នាក់ៗនៃកងកម្លាំងប្រដាប់អាវុធ មិនត្រូវបានចាត់ទុកថាជាជនស៊ីវិល ផ្អែកតាមខ្លឹមសារនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្តី ក៏មានមូលដ្ឋានរឹងមាំដែលថា ប្រជាជនមួយក្រុមគឺជា "ប្រជាជនស៊ីវិល" ប្រសិនបើប្រជាជនទាំងនោះជាជនស៊ីវិលភាគច្រើន[21]។ ដូច្នេះ វត្តមាននៃទាហានក្នុងចំណោមប្រជាជនស៊ីវិលដែលត្រូវបានកំណត់ជាគោលដៅដោយចេតនានោះ មិនបានផ្លាស់ប្តូរជាចាំបាច់នូវលក្ខណៈស៊ីវិលនៃប្រជាជននោះឡើយ[22]។ ផ្ទុយទៅវិញ សំណួរ

---

[21] សាលក្រមអង្គជំនុំជម្រះរឿងក្តី *Tadić* កថាខណ្ឌ ៦៣៨ (ត្រូវបានលើកឡើងនៅក្នុងសាលក្រមអង្គជំនុំជម្រះជាច្រើនរួមមាន សាលក្រមអង្គជំនុំជម្រះ *Blagojević និង Jokić* កថាខណ្ឌ ៥៤៤; សាលក្រមអង្គជំនុំជម្រះ *Karadžić* កថាខណ្ឌ ៤៧៤; សាលក្រមអង្គជំនុំជម្រះ *Kunarac*, សាលក្រមអង្គជំនុំជម្រះ *Milutinović និងអ្នកផ្សេងទៀត*។ សាលក្រមអង្គជំនុំជម្រះវុល ១ កថាខណ្ឌ ១៤៦)។

[22] សាលក្រមបណ្តឹងសាទុក្ខ *Blaškić* កថាខណ្ឌ ១១៥; សាលក្រមអង្គជំនុំជម្រះ *Karadžić* កថាខណ្ឌ ៤៧៤, កំណត់ចំណាំ ១៥៤៩; តុលាការឧក្រិដ្ឋកម្មអន្តរជាតិ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Jean-Pierre Bemba Gombo* សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ, ICC-01/05-01/08-3343, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងលើកទី ២, កថាខណ្ឌ ១៥៣។

ដែលសួរថាតើវត្តមានទាហាននឹងដកយកលក្ខណៈ "ជនស៊ីវិល" ពីប្រជាជនទាំងមូល ឬអត់ គឺអាស្រ័យលើកត្តាជាច្រើន[23]។

២៥. វាជារឿងច្បាស់ផងដែរដែលថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធអាចជា*ជនរងគ្រោះ* នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រសិនបើពួកគេត្រូវបានសម្លាប់ ឬរងរបួសដោយសារការវាយប្រហារដែលធ្វើឡើងប្រឆាំងនឹងប្រជាជន "ស៊ីវិល" (ពោលគឺប្រជាជនមិនមែនយោធា)។ ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងរឿងក្តី *Martić* "គ្មានអ្វីនៅក្នុងមាត្រា ៥ នៃលក្ខន្តិកៈរបស់ [តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី] ឬអាជ្ញាធរមុនៗនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍ដែលតម្រូវថាជនរងគ្រោះម្នាក់ៗនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវតែជាជនស៊ីវិល" នោះទេ[24]។ ហេតុនេះហើយ យ៉ាងហោចណាស់បុគ្គលទាំងឡាយដែល*បាត់បង់សមត្ថភាពប្រយុទ្ធ*អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឲ្យតែការវាយប្រហារដែលប៉ះពាល់លើពួកគេធ្វើឡើងប្រឆាំងនឹង "ប្រជាជនស៊ីវិល"[25]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានកត់សម្គាល់ថា ជំហរនេះគឺស្របគ្នាជាមួយនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចដែលបង្ហាញដោយអយ្យការក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងក្នុងទសវត្សរ៍ឆ្នាំ ១៩៤០[26]។

២៦. ដូច្នេះ ការពិតដែលថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធត្រូវបានកំណត់ជាគោលដៅដែលជាផ្នែកនៃការវាយប្រហារទូលំទូលាយប្រឆាំងនឹងប្រជាជនស៊ីវិលភាគច្រើន នឹងមិនផ្លាស់ប្តូរលក្ខណៈជនស៊ីវិលនៃប្រជាជននោះឡើយ។ ដូច្នោះហើយ បុគ្គលិកយោធាអាច នៅក្នុងកាលៈទេសៈខ្លះ ជា*ជនរងគ្រោះ*នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

២៧. នេះគឺជាយុទ្ធសាស្ត្រដែលអនុម័តដោយអង្គជំនុំជម្រះនៃ អ.វ.ត.ក មកទល់នឹងពេលបច្ចុប្បន្ននេះ។ នៅក្នុងបរិបទនៃសំណុំរឿង ០០១ និង ០០២/០១ អង្គជំនុំជម្រះនៃ អ.វ.ត.ក បានចាត់ទុកការវាយប្រហារដែលពាក់ព័ន្ធថាត្រូវបាន "ធ្វើឡើងសំដៅរកប្រជាជនកម្ពុជាទាំងមូល" និងថា បើទោះបីជាការវាយប្រហារនោះបានក្តោបយក "ទាំងជនស៊ីវិល និងទាំងជនយោធា ដោយគ្មានការបែងចែក" ក្តី

---

[23] សាលក្រមបណ្តឹងសាទុក្ខ *Blaškić*, កថាខណ្ឌ ១១៥។

[24] *Martić* (លេខ X) កថាខណ្ឌ ៣០៧។

[25] ដូចឯកសារខាងលើ កថាខណ្ឌ ៣០៧។

[26] ដូចឯកសារខាងលើ, ទំព័រ ៣០៩។

01298970



ក៏គេនៅតែអាចនិយាយបានថា ការវាយប្រហារនេះ “ត្រូវបានធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល” បានដែរ[27]។ សមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងអតីតទាហាននៃរបបមុនត្រូវបានគេចាត់ទុកថាជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាក់ទងទៅនឹងមន្ទីរស-២១[28] និងទួលពោធិ៍ជ្រៃ[29]។

## សេចក្ដីសន្និដ្ឋាន

២៨. ការអនុវត្តវិធីសាស្ត្រជាក់ស្តែងលើពាក្យថា “ជនស៊ីវិល” នៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បង្ហាញថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋដែលត្រូវបានវាយប្រហារដោយរដ្ឋផ្ទាល់របស់ពួកគេគប្បីត្រូវបានចាត់ទុកថាជាជនស៊ីវិលក្នុងស្ថានភាពពីរយ៉ាងគឺ៖

ក. ក្នុងករណីដែលបុគ្គលទាំងនោះត្រូវរងការវាយប្រហារ នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ ដោយសារតែភក្តីភាពដែលត្រូវសន្មត់ជាមួយភាគីមួយទៀតក្នុងជម្លោះ ឬដោយសារមូលហេតុដែលមិនទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ ជាពិសេសដោយសារមូលហេតុរើសអើង និង

ខ. ក្នុងករណីដែលការវាយប្រហារត្រូវបានប្រព្រឹត្តក្នុងពេលមានសន្តិភាព។

២៩. លើសពីនេះទៀត សមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋអាចត្រូវបានចាត់ទុកថាជា*ជនរងគ្រោះ* នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងករណីដែលឧក្រិដ្ឋកម្មប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធគឺជាផ្នែកនៃការវាយប្រហារកាន់តែធំប្រឆាំងនឹងប្រជាជន ដែលភាគច្រើនជា “ជនស៊ីវិល”។

ធ្វើនៅទីក្រុងស៊ីឌនី ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦

Sarah Williams Rosemary Grey

[27] អ.វ.ត.ក, សំណុំរឿង ០០១, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣២៥; អ.វ.ត.ក, សំណុំរឿង ០០២/០១ សាលក្រម, អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៩៣-៤។

[28] សំណុំរឿង ០០១, សាលក្រម, កថាខណ្ឌ ៣២៤-៥

[29] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៨២-៧។